ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
អង្គភាពគាំទ្រកម្មវិធី

លេខ......១១៧..........គ.ជ.អ.ប/អ.គ.ទ្រ.ក

រាជធានីភ្នំពេញ ថ្ងៃទី..០៧.. ខែ..មេសា.... ឆ្នាំ២០០៩

**ជម្រាបជូន**

**ឯកឧត្តមអភិបាលរាជធានី ខេត្ត និងជាប្រធានក្រុមការងារគណនេយ្យភាពរាជធានី ខេត្ត**

**កម្មវត្ថុ :** ស្តីពីនីតិវិធីទូទាត់ប្រាក់ឧបត្ថម្ភមន្ត្រីជំនួយការក្រុមគាំទ្រនៃក្រុមការងារគណនេយ្យភាព ។

**យោង :** -សេចក្តីសម្រេចលេខ ០១២ សសរ/គ.ជ.វ.វ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៨ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមការងារគណនេយ្យភាពជាតិ ។

-សេចក្តីសម្រេចលេខ ០១៣ សសរ/គ.ជ.វ.វ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតក្រុមគាំទ្រនៃក្រុមការងារគណនេយ្យភាពជាតិ ។

-សេចក្តីណែនាំលេខ ០១៤ សណន/គ.ជ.វ.វ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៨ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមការងារគណនេយ្យភាពខេត្ត ក្រុង ។

-លិខិតលេខ ៣០ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពីការរៀបចំ ឡើងវិញនូវក្រុមការងារគណនេយ្យភាពរាជធានី ខេត្ត និងការបង្កើតក្រុមគាំទ្រក្រុមការងារនៃក្រុមការងារគណនេយ្យភាពរាជធានី ខេត្ត ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបឯកឧត្តមអភិបាលរាជធានី ខេត្ត និងជាប្រធានក្រុមការងារគណនេយ្យភាពរាជធានី ខេត្តជ្រាបថា ដើម្បីធានាឱ្យការអនុវត្តយន្តការក្រុមការងារគណនេយ្យភាពមានប្រសិទ្ធភាពទាំងនៅថ្នាក់ជាតិ និងរាជធានី ខេត្ត គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិបានដាក់ចេញនូវសេចក្តីសម្រេចដែលបានកែសម្រួលថ្មីសម្រាប់បន្តពង្រឹងឡើងវិញនិងធ្វើការគាំទ្រដល់ដំណើរការអនុវត្តកិច្ចប្រតិបត្តិការរបស់ក្រុមការងារគណនេយ្យភាព ។ សេចក្តីសម្រេចថ្មីនេះតម្រូវឱ្យក្រុមការងារគណនេយ្យភាពទាំងនៅថ្នាក់ជាតិ និងរាជធានី ខេត្ត បង្កើតក្រុមគាំទ្រដោយមានមន្ត្រីជំនួយការដែលត្រូវជ្រើសរើសពី ១-៣ រូបបន្ថែម ដើម្បីជួយអនុវត្តការងារប្រចាំថ្ងៃឱ្យមានប្រសិទ្ធភាព ។ ក្នុងន័យនេះ រាជធានី ខេត្តត្រូវបង្កើនការយកចិត្តទុកដាក់ក្នុងការពង្រឹងឡើងវិញនូវក្រុមការងារគណនេយ្យភាពរាជធានី ខេត្តរបស់ខ្លួន និងចាត់វិធានការណ៍ឱ្យម៉ឺងម៉ាត់ ស្របតាមសេចក្តីណែនាំដែលបានដាក់ចេញដោយ គ.ជ.អ.ប ។ រាជធានី ខេត្តត្រូវធ្វើការជ្រើសរើសមន្ត្រីជំនួយការឱ្យបានឆាប់ដើម្បីចូលបំរើការងារ និងធ្វើការពង្រឹងសមត្ថភាពដល់មន្ត្រីទាំងនោះ ។

ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តការងាររបស់ក្រុមការងារគណនេយ្យភាព អង្គភាពគាំទ្រកម្មវិធី (PST) នៃលេខាធិការដ្ឋាន គ.ជ.អ.ប មានកិត្តិយសសូមធ្វើការណែនាំដូចខាងក្រោម៖

១. ត្រូវរៀបចំជ្រើសរើសមន្ត្រីជំនួយការក្រុមគាំទ្រ ពី១-៣ រូបដូចចំនួនដែលបានជូនភ្ជាប់ ។ មន្ត្រីដែលជ្រើសរើសនេះត្រូវចុះកិច្ចសន្យាការងារពេញម៉ោងជាមួយគណៈកម្មាធិការប្រតិបត្តិនៃ គ.អ.ជ.ខ ដោយទទួលបានប្រាក់ឧបត្ថម្ភចំនួន ៨០ ដុល្លារម្នាក់ក្នុងមួយខែ ។ គម្រោងវិនិយោគជនបទ និងអភិបាលកិច្ចមូលដ្ឋាន (RILGP) របស់ធនាគារពិភពលោក (WB) ជាអ្នករ៉ាប់រងការចំណាយទាំងនេះ ។

២. ការចំណាយពាក់ព័ន្ធនឹងប្រាក់ឧបត្ថម្ភប្រចាំខែរបស់មន្ត្រីជំនួយការក្រុមគាំទ្រនៃក្រុមការងារគណនេយ្យភាពរាជធានី ខេត្តទាំងអស់ ត្រូវទូទាត់ដោយផ្ទាល់ចេញពីគម្រោងការគាំទ្រការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ (PSDD) តាមរយៈគណនីធនាគាររបស់គម្រោង PSDD ។ ដូចនេះរាជធានី ខេត្តត្រូវធ្វើវិសោធនកម្មកិច្ចសន្យា GOV របស់ខ្លួន ដើម្បីបញ្ចូលបន្ថែមថវិកាសម្រាប់ការចំណាយប្រាក់ឧបត្ថម្ភរបស់មន្ត្រីជំនួយការក្រុមគាំទ្រដែលបានជ្រើសរើសស្របតាមចំនួនដូចបានជូនភ្ជាប់ ។ ចំនួនថវិកាដែលត្រូវធ្វើវិសោធនកម្មបន្ថែមនេះ ត្រូវគិតចាប់ពីថ្ងៃចាប់ផ្ដើមបំពេញការងាររហូតដល់បំណាច់ឆ្នាំ២០០៩ ។

៣. ក្រុមការងារបច្ចេកទេសរបស់ក្រុមគាំទ្រកម្មវិធីបានឯកភាពបង្កើតលេខកូដ NCD និងលេខកូដ Peachtree ថ្មីប្រើប្រាស់សម្រាប់កត់ត្រាព័ត៌មានស្ដីពីការចំណាយនេះ និងដើម្បីផ្ដល់ព័ត៌មានឱ្យថ្នាក់ជាតិបានដឹងអំពីចំនួនថវិកាដែលបានចំណាយចេញពីគម្រោង PSDD សម្រាប់ប្រាក់ឧបត្ថម្ភរបស់មន្ត្រីជំនួយការក្រុមគាំទ្រនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។ គណៈកម្មាធិការប្រតិបត្តិនៃរាជធានី ខេត្ត ត្រូវរួមសហការជាមួយប្រធានទីប្រឹក្សា និងទីប្រឹក្សាផ្នែកហិរញ្ញវត្ថុប្រចាំរាជធានី ខេត្ត ដើម្បីធានាក្នុងការបញ្ចូលលេខកូដគណនីថ្មីនេះក្នុងប្រព័ន្ធគណនេយ្យ Peachtree ប្រើប្រាស់សម្រាប់កត់ត្រាការទូទាត់ប្រាក់ឧបត្ថម្ភប្រចាំខែដល់មន្ត្រីជំនួយការក្រុមគាំទ្រ ហើយបង្ហាញទិន្នន័យចំណាយទាំងនេះក្នុងរបាយការណ៍ហិរញ្ញវត្ថុប្រចាំខែ ។ ចំពោះការណែនាំលំអិតស្ដីពីលេខកូដ NCD និង Peachtree នឹងមានជូននៅពេលក្រោយ ។

៤. នៅពេលដែលអង្គភាពគាំទ្រកម្មវិធីធ្វើការទូទាត់ថ្លៃប្រេងឥន្ធនៈ អង្គភាពគាំទ្រកម្មវិធីនឹងចាត់បន្ទុកចំណាយដែលស្មើទៅនឹងចំនួនថវិកាសរុបបានទូទាត់សម្រាប់ប្រាក់ឧបត្ថម្ភប្រចាំខែរបស់ក្រុមមន្ត្រីគាំទ្រ ជាបន្ទុកចំណាយរបស់គម្រោងការវិនិយោគជនបទ និងអភិបាលកិច្ចមូលដ្ឋាន (RILGP) ហើយធ្វើការទូទាត់ផ្ទាល់ចេញពីគណនីធនាគារគម្រោងនេះនៅថ្នាក់ជាតិ ។ នេះមានន័យថាប្រសិនបើការទូទាត់សម្រាប់មន្ត្រីជំនួយការក្រុមគាំទ្ររាជធានី ខេត្តទាំង២៤ មានចំនួនសរុប US$3,300 នោះគម្រោង RILGP នឹងជួយធ្វើការទូទាត់ថ្លៃប្រេងឥន្ធនៈចំនួន US$3,300 ជូនអង្គភាពគាំទ្រកម្មវិធីវិញ ( គម្រោង PSDD នៅថ្នាក់ជាតិ) ។

៥. ដើម្បីអោយការទូទាត់ចេញពីគណនីគម្រោង RILGP មានសុពលភាព មន្ត្រីហិរញ្ញវត្ថុអង្គភាពគាំទ្រកម្មវិធីត្រូវថតចំលងរបាយការណ៍ លំហូរសាច់ប្រាក់របស់គម្រោង PSDD សម្រាប់ធ្វើការផ្ទៀងផ្ទាត់មុនពេលធ្វើការទូទាត់ ហើយត្រូវថតចំលងវិក័យប័ត្រប្រេងឥន្ធនៈដែលមានចែងនៅក្នុងចំណុចទី៤ខាងលើ សម្រាប់ជាឯកសារយោងគាំទ្រការចំណាយប្រាក់ ឧបត្ថម្ភប្រចាំខែ ។

៦. នីតិវិធីខាងលើនេះ នឹងត្រូវអនុវត្តចំពោះការចំណាយសម្រាប់ប្រាក់ខែមន្ត្រីជំនួយការក្រុមគាំទ្រនៃក្រុមការងារគណនេយ្យភាពជាតិដែរ (ប្រាក់ឧបត្ថម្ភនឹងមាន ឧបសម្ព័ន្ធមួយដោយឡែក) ។ ក្នុងករណីដែលចំនួនថវិកា

សរុបបានទូទាត់ដល់មន្ត្រីជំនួយការក្រុមគាំទ្រនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្នុង រយៈពេលមួយខែ ច្រើនជាងតម្លៃប្រេងឥន្ធនៈសរុបដែលប្រើប្រាស់ដោយអង្គភាពគាំទ្រកម្មវិធី នោះថវិកាដែលសល់នេះនឹងត្រូវធ្វើការទូទាត់សម្រាប់ថ្លៃប្រេងឥន្ធនៈដែលមាននៅក្នុងកិច្ចសន្យារវាងគម្រោង PSDD ជាមួយនឹងនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន (DoLA) ។

៧. នីតិវិធីខាងលើនឹងចូលជាធរមាន ចាប់ពីខែដែលប្រាក់ឧបត្ថម្ភត្រូវបានទូទាត់ដល់មន្ត្រីជំនួយការក្រុមគាំទ្រនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចូលបំរើការងារ ។

អាស្រ័យហេតុនេះ សូមឯកឧត្តមជ្រាបជាព័ត៌មាន និងចាត់ចែង តាមការគួរ ។

សូមឯកឧត្តម មេត្តាទទួលនូវការគោរពរាប់អានដ៏ស្មោះពីខ្ញុំ ។

**អង្គភាពគាំទ្រកម្មវិធីនៃលេខាធិការដ្ឋាន គ.ជ.អ.ប**

**ជ. នាយក**

**លេង វី**

*ចម្លងជូន:*

-ក្រុមការងារគណនេយ្យភាពជាតិ

-គម្រោង PSDD

-ធនាគារពិភពលោក

" ដើម្បីជ្រាប "

-ឯកសារ កាលប្បវត្តិ